**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់ «វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត» សរសេរជាអក្សរកាត់ «វ.អ.ន» ដែលមានឈ្មោះជាភាសាអង់គ្លេសថា «Student Development Institute» សរសេរជាអក្សរកាត់ «S.D.I» ។

**មាត្រា២.-**

វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត មានទីតាំងនៅអគារលេខ៨៤ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣.-**

វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត ធ្វើការបណ្តុះបណ្តាលៈ

- កម្រិតវិញ្ញាបនបត្រ សិក្សារយៈពេលក្រោម ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ០២ឆ្នាំ ត្រូវនឹង ៦០ក្រេឌីតឡើងទៅ
- កម្រិតវិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ០៤ឆ្នាំ ត្រូវនឹង ១២០ក្រេឌីតឡើងទៅ។

**មាត្រា៤.-**

ចំពោះមុខ វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យសិក្សា
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យបច្ចេកទេស
- មហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម
- មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាន
- មហាវិទ្យាល័យអេឡិចត្រូនិច-អគ្គិសនី

នៅថ្ងៃអនាគត វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត អាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៥.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឱ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្រៈ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររងៈ បេក្ខជនមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតវិស្វករ ឬបរិញ្ញាបត្រៈ បេក្ខជនមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋាននានារបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើស ការបណ្តុះបណ្តាល និងការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស-និស្សិត ។

**មាត្រា៦.-**

វិទ្យាស្ថានអភិវឌ្ឍន៍និស្សិតមាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចំបាច់។ នាយកវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត មានភារកិច្ច ៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀតទាត់តាមការកំណត់។

**មាត្រា៧.-**

សិស្ស-និស្សិតវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត ហើយត្រូវបានទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត បំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានអភិវឌ្ឍន៍និស្សិត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ